-មានសិទ្ធិប្រើត្រា របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តន៏ភារកិច្ចពាក់ព័ន្ធចាំបាច់ ។

**ប្រការ ៤ :** ក្រសួងស្ថាប័ននីមួយៗ ត្រូវបញ្ជូនឈ្មោះនិងមុខងារនៃតំណាងរបស់ខ្លួន ដូចមានចែងក្នុងប្រការ១ មកប្រធានគណៈកម្មការចំរុះនេះ ដើម្បីងាយស្រួលក្នុងការបំពេញភារកិច្ចរបស់គណៈកម្មការ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៏ជនបទ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន អគ្គលេខាធិការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៏ជនបទកម្ពុជា ប្រធានក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## ៣- សេចក្តីប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០០

### សេចក្តីប្រកាស

### សេចក្តីប្រកាស លេខ ០៣ ប្រក

### របស់រាជរដ្ឋាភិបាល

### ស្តីពីការអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារនៅកម្ពុជា

* * *

កៅស៊ូធម្មជាតិ គឺជាដំណាំកសិ-ឧស្សាហកម្ម ដែលបានផ្តល់ផលប្រយោជន៏យ៉ាងសំខាន់ សំរាប់សេដ្ឋកិច្ចជាតិ ។ ជារៀងរាល់ឆ្នាំ ប្រទេសកម្ពុជាបានស្រូបយករូបិយប័ណ្ណយ៉ាងច្រើនដែលបានមកពីការនាំចេញផលិតផលកៅស៊ូធម្មជាតិ ។

ប្រទេសកម្ពុជាមានដីក្រហម និងដីប្រភេទផ្សេងៗទៀតរាប់សែនហិកតាដែលមានសក្តានុពលអាចដាំដុះកៅស៊ូបាន ប៉ុន្តែរហូតមកទល់បច្ចុប្បន្ននេះ យើងនៅពុំទាន់បានប្រើប្រាស់អោយអស់សក្តានុពលនេះនៅឡើយ ។

ការដាំដុះកៅស៊ូឡើងវិញស្ថិតនៅក្នុងស្ថានភាពមួយបើតយ៉េរ និងមិនទាន់សមស្របតាមសភាពការណ៍ នៃការអភិវឌ្ឍន៍ដំណាំកៅស៊ូនៅទូទាំងប្រទេសនៅឡើយ ។

ម្យ៉ាងទៀតក្នុងរយះពេលប៉ុន្មានឆ្នាំកន្លងមកនេះ និន្នាការនៃតម្លៃកៅស៊ូធម្មជាតិនៅលើទីផ្សារអន្តរជាតិ បានធ្លាក់ចុះយ៉ាងខ្លាំង ដែលមិនធ្លាប់មានសោះតាំងពីមុនមក តែតម្លៃកៅស៊ូនឹងងើបឡើងវិញនៅក្នុងអនាគតដ៏ខ្លីខាងមុខ ហើយដំណាំកៅស៊ូនៅតែរក្សាបានតួនាទីមួយដ៏សំខាន់យ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចជាតិ ។

ដើម្បីអោយដំណាំកៅស៊ូមានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សលើគ្រប់ផ្នែក ទាំងផ្នែកកសិ-ឧស្សាហកម្ម ទាំងផ្នែកឯកជន និងជាពិសេសផ្នែកដំណាំកៅស៊ូគ្រួសារ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ផ្តល់អាទិភាពខ្ពស់ដល់ដំណាំនេះ ដោយបានកំណត់នៅក្នុងកម្មវិធីនយោបាយរបស់ខ្លួនក្នុងអាណត្តិទី២ ថា "<u>រាជរដ្ឋាភិបាលនឹងលើកទឹកចិត្តដល់កសិករ អោយដាំដំណាំកៅស៊ូនៅលើចំការតូចតាចរបស់ខ្លួន តាមគោលនយោបាយ នៃការផ្តល់ឥណទាន ការផ្តល់សិទ្ធិលើការកាន់កាប់ និងការប្រើប្រាស់ដីធ្លីអោយបានសមស្រប</u> " ។

គោលបំណងដ៏សំខាន់របស់រាជរដ្ឋាភិបាល ក្នុងការជំរុញការអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ គឺសំដៅ :

* អភិវឌ្ឍន៍ដំណាំកៅស៊ូនៅកម្ពុជាអោយបានរីកចំរើនឆាប់រហ័ស ។
* ជួយបង្កើនប្រាក់ចំណូល ដែលបានមកពីការធ្វើអាជីវកម្មកៅស៊ូដល់កសិករ និងជួយកាត់បន្ថយភាពក្រីក្រនៅតាមជនបទ ។
* បង្កើនប្រភពប្រាក់ចំណូលដល់ខឿនសេដ្ឋកិច្ចជាតិ តាមរយះការនាំចេញផលិតផលកៅស៊ូ ។
* ជួយការពារបរិស្ថានទល់នឹងភាពហួតហែងក្តៅខ្លាំងនៃធម្មជាតិ និងការហូរច្រោះដី ។

គោលនយោបាយអភិវឌ្ឍន៍នេះ គឺសំដៅជួយកសិករតូចតាចអោយដាំដំណាំកៅស៊ូដែលមានទិន្នផលខ្ពស់ រួមទាំងដំណាំកសិផលផ្សេងៗទៀតនៅតាមចន្លោះរងកៅស៊ូ សំរាប់ធានាជីវភាពរស់នៅរបស់កសិផល រហូតដល់រយះពេលនៃការចាប់ផ្តើមចៀរជ័រកៅស៊ូ ។

កសិករដែលស្ម័គ្រចិត្តចូលរួមក្នុងគំរោងអភិវឌ្ឍន៍នេះ ត្រូវបានរាជរដ្ឋាភិបាលធានា និងលើកទឹកចិត្ត ដោយ :

• ផ្តល់ជូននូវសិទ្ធិក្នុងការកាន់កាប់ ការប្រើប្រាស់ដីចំការ ការបន្តមរតក ឬការផ្ទេរសិទ្ធិអោយអ្នកដទៃ ព្រមទាំងរដ្ឋធានាមិនធ្វើជាតូបនីយកម្មឡើយ ។

• សំរួលដល់ការខ្ចីឥណទានតាមរយះធនាគារអភិវឌ្ឍន៍ជនបទតាមលក្ខខណ្ឌ និងវិធីសាស្ត្រនានាដែលមាន

• ផ្តល់ជូននូវការបណ្តុះបណ្តាល និងសេវាបច្ចេកទេសក្នុងការដាំដុះ ការថែទាំ រហូតដល់ការប្រមូលផល ព្រមទាំងផ្តល់ពត៌មាន ស្តីពីទីផ្សារផលិតផលកៅស៊ូ ។

• ផ្តល់នូវសិទ្ធិក្នុងការទទួលផលពីចំការរបស់ខ្លួន ការកែច្នៃ និងការលក់ដូរផលិតផលកៅស៊ូដោយសេរី ។

• កសិករមានសិទ្ធិរៀបចំសមាគមកសិករដាំកៅស៊ូ សំរាប់ការពារផលប្រយោជន៍របស់សមាជិកម្នាក់ៗ ។

រាជរដ្ឋាភិបាលសង្ឃឹមថា ប្រជាកសិករនៅទូទាំងប្រទេសនឹងចូលរួមយ៉ាងសកម្មនៅក្នុងការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារ សំរាប់លើកស្ទួយសេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ខ្លួនប្រកបដោយសុភមង្គល ។

ទទួលបានសេចក្តីប្រកាសនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈកម្មការតាមដាន និង ជំរុញការអនុវត្តន៍គំរោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយអោយបានទូលំទូលាយ និងខិតខំអនុវត្តការងារនេះ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ព្រមទាំងរាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលការងារដែលសំរេចបាន និងបញ្ហានានាដែលកើតឡើង ដើម្បីមានវិធានការណ៍ជាក់ស្តែង ។

នាយករដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
ហ៊ុន សែន

***

## III- ការងារបណ្តាក្រសួង

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០០

**ទីស្តីការដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

**ប្រកាស**

**ប្រកាស លេខ ៩០០ អយក.ប្រក**

**ស្តីពីការពង្រីក អនុវិទ្យាល័យ "ក្រួចឆេះពនិមិត្ត ហ៊ុន សែន "**

**ទៅជាវិទ្យាល័យ "ក្រួចឆេះពនិមិត្ត ហ៊ុន សែន " ស្ថិតនៅក្នុងសង្កាត់**

**ទួលល្វា ខ័ណ្ឌ ប៉ៃលិន ក្រុង ប៉ៃលិន ។**

* * *

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា